**សលាកប័ត្រព័ត៌មាន៖ <u>អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ានៅព្រះរាជាណាចក្រកម្ពុជា</u>**

**ទិដ្ឋភាពរួម៖** "ម៉ុងតាញ៉ា" គឺជាពាក្យប្រើសម្រាប់ពិពណ៌នាក្រុមជនជាតិភាគតិចផ្សេងៗដែលរស់នៅភាគច្រើននៅតាមតំបន់ខ្ពង់រាបនៃប្រទេសវៀតណាម។ ក្រុមម៉ុងតាញ៉ាភាគច្រើនប្រតិបត្តិតាមគ្រិស្តសាសនា និងបានរងការធ្វើទុក្ខបុកម្នេញជាខ្លាំងផ្នែកនយោបាយ និង/ឬសាសនា ពីសំណាក់អាជ្ញាធរក្នុងប្រទេសវៀតណាម។ ជារឿយៗ ប្រទេសកម្ពុជាខ្វះខាតក្នុងការបំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិក្នុងការការពារម៉ុងតាញ៉ាដែលស្វែងរកសិទ្ធិជ្រកកោនក្នុងប្រទេសកម្ពុជា ដែលឈានទៅដល់ការបញ្ជូនជនភៀសខ្លួនម៉ុងតាញ៉ាចេញដោយបង្ខំទៅកាន់ប្រទេសដើមរបស់ពួកគេវិញ ដែលនៅទីនោះពួកគេប្រឈមនឹងការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗទៀត។

សលាកប័ត្រព័ត៌មាននេះតាក់តែងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

**សាវតារ**

ម៉ុងតាញ៉ា[1] ដែលគេថា "ដេហ្គា"[2] គឺជាក្រុមជនជាតិដើមភាគតិចនៅភាគខាងជើងនៃប្រទេសវៀតណាម និងតាមតំបន់ខ្ពង់រាបកណ្តាល។ ម៉ុងតាញ៉ាគឺជាគោលដៅនៃការបង្ក្រាប និងការមិនរាប់បញ្ចូលយូរមកហើយ ជាពិសេសជនភាគតិចដែលកាន់គ្រិស្តសាសនាដែលប្រតិបត្តិតាមវិហារសាសនាគ្រិស្ត ឬវិហារកាតូលិក។[3] ក្នុងអំឡុងពេលសង្គ្រាមនៅឥណ្ឌូចិនលើកទីមួយ និងលើកទីពីរ ម៉ុងតាញ៉ាបានចូលរួមប្រយុទ្ធអមជាមួយនឹងបារាំង និងសហរដ្ឋអាមេរិក ដែលបង្កឱ្យមានការធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់ទៅលើក្រុមម៉ុងតាញ៉ារហូតមកដល់បច្ចុប្បន្ននេះ ដោយមានទំនាស់ទាក់ទងនឹងដីធ្លី។

បន្ទាប់ពីការធ្វើជាតូបនីយកម្មដីធ្លីក្នុងឆ្នាំ១៩៧៥[4] ម៉ុងតាញ៉ាជាច្រើនត្រូវបានបង្ខំឱ្យប្រគល់ដីធ្លីរបស់ពួកគេឱ្យទៅអាជ្ញាធរវៀតណាម។ ទំនាស់ទាំងនេះបានបង្កឱ្យមានការតវ៉ានៅខែកុម្ភៈ ឆ្នាំ២០០១ ដោយមានការចូលរួមពីម៉ុងតាញ៉ាជាច្រើនពាន់នាក់ដែលទាមទារដីធ្លីពីរដ្ឋាភិបាលមកវិញ និងទាមទារឱ្យមានការគោរពសេរីភាពខាងសាសនារបស់ពួកគេ។ រដ្ឋាភិបាលបានឆ្លើយតបតាមរយៈការគាបសង្កត់ជាខ្លាំងផ្នែកនយោបាយដើម្បី

---

[1] ជាភាសាបារាំង មានន័យថា "មនុស្សរស់នៅតាមព្រៃភ្នំ" ឬ "មនុស្សភ្នំ"។

[2] ពាក្យដែលត្រូវបានជនជាតិដើមខ្លួនឯងប្រើដោយសម្តៅទៅលើ "មនុស្សដើម" នៃតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម http://bit.ly/2oHWjQ4។

[3] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ការធ្វើទុក្ខបុកម្នេញ "មាគ៌ាឃោរឃៅ"នៃសាសនា ការរំលោភបំពានទៅលើក្រុមម៉ុងតាញ៉ានៅក្នុងប្រទេសវៀតណាម" (ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥) https://goo.gl/0Nnlda (អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ២០១៥)

[4] គោលនយោបាយនៃការរឹបអូសដីធ្លីរបស់ម្ចាស់ដី និងអ្នកមាន ហើយធ្វើការបែងចែកដីជូនដល់ប្រជាពលរដ្ឋក្រីក្រ និងកសិករដែលគ្មានដី និងក្រោយមករៀបចំប្រជាពលរដ្ឋនៅតាមទីជនបទឱ្យទៅជាសមូហភាព។

បញ្ឈប់ការតវ៉ា ដោយមានទាំងការចាប់ខ្លួន និងធ្វើឱ្យអ្នកតវ៉ាដោយសន្តិវិធីរាប់រយនាក់រងរបួស។[5] ការតវ៉ាបន្តទៀតក្នុងខែមេសា ឆ្នាំ២០០៤ ក៏បានរងការបង្ក្រាបដោយពុំសមាមាត្រពីកងកម្លាំងសន្តិសុខវៀតណាម និងបានបណ្តាលឱ្យម៉ុងតាញ៉ាជាច្រើននាក់ព្យាយាមរត់ភៀសខ្លួនចេញពីប្រទេស។[6] ក្នុងឆ្នាំ២០១៣ រដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តយន្តការច្បាប់ដើម្បីជានាការគ្រប់គ្រងលើការប្រតិបត្តិផ្នែកសាសនា ដែលនាំឱ្យចំនួនជនភៀសខ្លួនពីប្រទេសវៀតណាមមកកាន់ប្រទេសកម្ពុជាកាន់តែកើនឡើងជាខ្លាំងចាប់តាំងពីឆ្នាំ២០១៣។[7] អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសេរីភាពខាងសាសនានិងជំនឿ ("អ្នករាយការណ៍ពិសេស") បានធ្វើសេចក្តីសន្និដ្ឋានបន្ទាប់ពីទស្សនៈកិច្ចទៅកាន់ប្រទេសវៀតណាមនៅឆ្នាំ២០១៤ ថា "*ស្វ័យភាព និងសកម្មភាពឯករាជ្យរបស់សហគមន៍ខាងសាសនា ឬជំនឿ [...] នៅតែរងការរឹតត្បិត និងពុំមានសុវត្ថិភាព ដោយសិទ្ធិសេរីភាពខាងសាសនា ឬជំនឿរបស់សហគមន៍ទាំងនេះរងការរំលោភបំពានជាខ្លាំងនៅចំពោះមុខនៃការឃ្លាំមើលជាទៀងទាត់ ការបំភិតបំភ័យ ការយាយី និងការធ្វើទុក្ខបុកម្នេញ*"។[8] ក្នុងប្រទេសវៀតណាម គ្រាន់តែរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០១៦ យ៉ាងហោចណាស់មានម៉ុងតាញ៉ាចំនួន៩នាក់ត្រូវបានកាត់ទោសពីបទ "ធ្វើឱ្យប៉ះពាល់ឯកភាពជាតិ" និងត្រូវបានកាត់ទោសដាក់ពន្ធនាគារចន្លោះពី ៥ ឆ្នាំ ដល់ ១១ ឆ្នាំ ដោយសារចូលរួមក្នុងក្រុមសាសនាឯករាជ្យដែលពុំទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល។[9]

ចាប់តាំងពីបាតុកម្មក្នុងឆ្នាំ២០០១ យ៉ាងហោចណាស់មានម៉ុងតាញ៉ា ចំនួន៣.០០០នាក់ បានឆ្លងព្រំដែនដើម្បីស្វែងរកសិទ្ធិជ្រកកោនក្នុងប្រទេសកម្ពុជា។[10] ដើម្បីការពារម៉ុងតាញ៉ាមិនឱ្យឆ្លងព្រំដែន រដ្ឋាភិបាលវៀតណាម និងកម្ពុជាបានបង្កើនចំនួនមន្ត្រីការពារនៅតាមព្រំដែន។ មន្ត្រីកម្ពុជាបានចាត់ទុកសមាជិកក្រុមជនជាតិភាគតិចនេះថាជា "ជនអន្តោប្រវេសន៍សេដ្ឋកិច្ចខុសច្បាប់" ជំនួសអ្នកស្វែងរកសិទ្ធិជ្រកកោន ឬជនភៀសខ្លួន និងបដិសេធទទួលស្គាល់ពីហានិភ័យជុំវិញការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានសិទ្ធិមនុស្សរបស់ក្រុមម៉ុងតាញ៉ា។[11] ស្ថានភាពធ្ងន់ធ្ងរបំផុត មានករណីជាច្រើនដែលអ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាបានត្រឡប់ទៅប្រទេសវៀតណាមវិញ ដែលជាការបំពានទៅលើគោលការណ៍ច្បាប់ជាមូលដ្ឋាននៃការមិនបញ្ជូនចេញដោយបង្ខំ (*សូមមើលខាងក្រោម*)។ ការរឹតត្បិតរបស់រដ្ឋាភិបាលវៀតណាមទៅលើក្រុមការងារផ្នែកសិទ្ធិមនុស្ស រួមទាំងអ្នក

---

[5] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ២០១៥

[6] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ២០១៥

[7] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ២០១៥

[8] របាយការណ៍របស់អ្នករាយការណ៍ពិសេសទទួលបន្ទុកផ្នែកសេរីភាពសាសនា ឬជំនឿ ផ្នែកបន្ថែម៖ បេសកកម្មទៅកាន់ប្រទេសវៀតណាមនៅថ្ងៃទី២១-៣១ ខែកក្កដា ឆ្នាំ២០១៤ (ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥) A/HRC/28/66/Add ឯកសារសង្ខេប និងកថាខ័ណ្ឌទី៦៩។

[9] សូមមើល "របាយការណ៍សកលឆ្នាំ២០១៧" របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រង់ជំពូកទាក់ទងនឹងប្រទេសវៀតណាម http://bit.ly/2oafjv6

[10] គម្រោងស្តារជីវភាពរស់នៅនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន http://bit.ly/2oWEgsK

[11] ឃួន ណារិម និង ចច្ច រ៉ៃយ៍, "ក្រសួងលើកឡើងថា "ម៉ុងតាញ៉ាពុំមែនជាជនភៀសខ្លួនទេ", សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/2q3vRCi

រាយការណ៍ពិសេស មិនឱ្យចូលទៅកាន់តំបន់ដែលម៉ុងតាញ៉ារស់នៅក្នុងប្រទេសវៀតណាម បានធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពនៃការឃ្លាំមើលចំពោះការប្រព្រឹត្តលើអ្នកទាំងនោះបន្ទាប់ពីការធ្វើមាតុភូមិនិវត្តន៍[12] ហើយអ្នកស្វែងរកសិទ្ធិជ្រកកោនមួយចំនួនបានរាយការណ៍ថា ម៉ុងតាញ៉ាដទៃទៀតដែលបានត្រឡប់ពីកម្ពុជាទៅកាន់ប្រទេសវៀតណាមបានប្រឈមនឹងការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរវៀតណាម។[13]

ក្នុងឆ្នាំ២០១៤ អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាចំនួន១៣នាក់ មកពីប្រទេសវៀតណាមបានចំណាយពេលច្រើនជាងប្រាំពីរសប្តាហ៍លាក់ខ្លួនក្នុងព្រៃក្នុងខេត្តរតនៈគិរី ដោយសារភ័យខ្លាចនឹងការចាប់ខ្លួន និងនិរទេសខ្លួនពីសំណាក់អាជ្ញាធរកម្ពុជា។ ក្នុងឆ្នាំ២០១៥ អាជ្ញាធរកម្ពុជាបានរារាំងតំណាងមកពីអង្គការសហប្រជាជាតិមិនឱ្យចូលទៅជួបអ្នកស្វែងរកសិទ្ធិជ្រកកោនទាំងនោះ និងត្រូវបានរាយការណ៍ថាបានគំរាមអ្នកភូមិក្នុងមូលដ្ឋាន និងអង្គការសិទ្ធិមនុស្សដែលអាចកំពុងតែព្យាយាមជួយអ្នកទាំងនោះ។[14] នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស និងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន បានសម្តែងការព្រួយបារម្ភថា "*មានមូលដ្ឋានរឹងមាំដែលគួរឱ្យជឿមួយចំនួនថា ជនជាតិភាគតិចម៉ុងតាញ៉ាអាចប្រឈមទៅនឹងគ្រោះថ្នាក់នៃការរំលោភបំពានសិទ្ធិមនុស្ស ប្រសិនបើពួកគេត្រូវបានបញ្ជូនត្រឡប់ទៅកាន់ប្រទេសកំណើតរបស់ខ្លួនគឺប្រទេសវៀតណាមវិញ*"។[15] ទីបំផុត ម៉ុងតាញ៉ាទាំង១៣នាក់បានទទួលសិទ្ធិជ្រកកោន និងបន្ទាប់ពីមានសេចក្តីសម្រេចដែលគួរឱ្យស្វាគមន៍របស់រដ្ឋាភិបាល ដើម្បីពន្យារកាលបរិច្ឆេទសម្រាប់ជនភៀសខ្លួនម៉ុងតាញ៉ា និងអ្នកស្វែងរកសិទ្ធិជ្រកកោនដែលពុំបានចុះបញ្ជីក្នុងការចាកចេញពីកម្ពុជារហូតដល់រយៈពេលបីខែ ដើម្បីអនុញ្ញាតឱ្យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន អាចស្វែងរកជម្រើសសម្រាប់ការតាំងលំនៅថ្មីដល់អ្នកទាំង១៣នាក់[16] ពួកគេបានចាកចេញទៅកាន់ប្រទេសហ្វីលីពីនដើម្បីរង់ចាំទៅតាំងទីលំនៅថ្មីនៅក្នុងប្រទេសទីបី។[17]

---

12 អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ២០១៥

13 ចច្ច រ៉ៃយ៍ និងអូន ភាព, "ម៉ុងតាញ៉ាដែលត្រូវបានបញ្ជូនចេញរិះគន់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាល", សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2pjAlGU

14 អូន ភាព និង ខូលីន ម៉ែន, "អង្គការសហប្រជាជាតិត្រូវបានហាមឃាត់មិនឱ្យជួបម៉ុងតាញ៉ា ខណៈម៉ុងតាញ៉ាបន្ថែមទៀតមកដល់កម្ពុជា", សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧) http://bit.ly/2pIrqzZ

15 មណ្ឌលព័ត៌មានអង្គការសហប្រជាជាតិ, "កម្ពុជា៖ អង្គការសហប្រជាជាតិព្រមានថា "មានមូលដ្ឋានជាច្រើន"ដែលជឿថា ម៉ុងតាញ៉ាអាចមានគ្រោះថ្នាក់" (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤) http://bit.ly/2pFtPIf

16 ផាក់ ស៊ាងលី និង អាលីស យូឌី, "ពន្យារការនិរទេសខ្លួនអ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាទៅវៀតណាម" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥) http://bit.ly/1RV6Osy

17 អ៊ើរីន ហែនលី, "ជនភៀសខ្លួនម៉ុងតាញ៉ាចេញដំណើរទៅកាន់ប្រទេសហ្វីលីពីន" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦) http://bit.ly/2oSpeCD

## ក្របខ័ណ្ឌច្បាប់

### *សិទ្ធិទទួលបានការជ្រកកោន*

**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស** ("ស.ស.ស.ម") មាត្រា១៤ ការពារសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការស្វែងរក និងទទួលបានសិទ្ធិជ្រកកោនក្នុងប្រទេសផ្សេងទៀត ហើយ ស.ស.ស.ម និង**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")** ដែលកម្ពុជាគឺជារដ្ឋភាគី ធានាសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការចាកចេញពីប្រទេសណាមួយ ក្នុងនោះរួមទាំងប្រទេសរបស់ខ្លួនផងដែរ។[18] សិទ្ធិដែលមានធានាដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិការពារបុគ្គលគ្រប់រូបដែលស្ថិតក្រោមយុត្តាធិការរបស់កម្ពុជា ដោយមិនគិតពីឋានៈជាជនអន្តោប្រវេសន៍របស់ពួកគេឡើយ ក្នុងនោះរួមទាំងជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោនផងដែរ។

**អនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១**[19] ដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី ផ្តល់និយមន័យជនភៀសខ្លួនថាៈ ជាជនទាំងឡាយណាដែល "*អាស្រ័យដោយមានការភ័យខ្លាចមានមូលដ្ឋានច្បាស់លាស់ចំពោះការធ្វើទុក្ខបុកម្នេញដោយហេតុផលពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមណាមួយ ឬដោយសារមតិនយោបាយនៅក្រៅប្រទេសដែលខ្លួនមានសញ្ជាតិ និងមិនអាច ឬដោយសារការភ័យខ្លាចនេះ មិនចង់ប្រើប្រាស់ការការពាររបស់ប្រទេសនោះ [...]*។"

ជារឿយៗ ជនដែលបានចាកចេញពីប្រទេសរបស់ពួកគេដើម្បីស្វែងរកសិទ្ធិជ្រកកោននៅក្រៅប្រទេសបានឆ្លងកាត់ព្រំដែនដោយខុសច្បាប់ ប៉ុន្តែអនុសញ្ញាស្តីពីជនភៀសខ្លួនហាមប្រាមយ៉ាងច្បាស់ចំពោះរដ្ឋនានាពីការដាក់ទោសទណ្ឌលើអ្នកស្វែងរកសិទ្ធិជ្រកកោនដែលចូល ឬមានវត្តមានក្នុងដែនដីរបស់រដ្ឋនោះដោយពុំមានការអនុញ្ញាត។[20] អ្នកស្វែងរកសិទ្ធិជ្រកកោនទាំងអស់ សូម្បីតែអ្នកដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ក្តី មានសិទ្ធិសេរីភាពខាងសាសនា[21] សិទ្ធិកាន់កាប់កម្មសិទ្ធិចលនទ្រព្យ និងអចលនទ្រព្យ[22] សិទ្ធិទទួលបានការអប់រំបឋម[23] និងសិទ្ធិចូលទៅកាន់តុលាការ។[24] ការរឹតត្បិតទាំងឡាយណាទៅលើសកម្មភាពផ្លាស់ទីរបស់ពួកគេ (ដូចជាបម្រាមគោចរ ការតម្រូវឱ្យរាយការណ៍ ឬលំនៅដ្ឋានជាក់លាក់ណាមួយ) ត្រូវតែមានភាព "ចាំបាច់"[25] និងគោរពតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានថ្លែងថា "ការឃុំខ្លួនអ្នកស្វែងរកសិទ្ធិជ្រកកោនគួរតែជាវិធានការចុងក្រោយបង្អស់ ដោយ

---

[18] មាត្រា ១១ នៃ ក.អ.ស.ព.ន និងមាត្រា ១៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

[19] អនុសញ្ញាឆ្នាំ១៩៥១ស្តីពីឋានៈនៃជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ (អនុសញ្ញាទីក្រុងហ្សឺណែវ) និងពិធីសារបន្ថែមឆ្នាំ១៩៦៧ ទាក់ទងទៅនឹងឋានៈនៃជនភៀសខ្លួន http://bit.ly/2ah31bH ("អនុសញ្ញាជនភៀសខ្លួន")

[20] មាត្រា៣១(១) នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[21] មាត្រា៤ នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[22] មាត្រា១៣ នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[23] មាត្រា២២ នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[24] មាត្រា១៦ (១) នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[25] មាត្រា៣១ (២) នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

ឈរលើគោលការណ៍សេរីភាពជាជម្រើសទូទៅ"។[26] ប្រសិនបើអនុវត្តការឃុំខ្លួន ការឃុំខ្លួននេះត្រូវតែអនុលោមតាមច្បាប់ និងផ្តល់សម្អាងហេតុដោយមានគោលបំណងត្រឹមត្រូវតាមច្បាប់ ហើយលក្ខខណ្ឌនៃការឃុំខ្លួនត្រូវធ្វើឡើងដោយមនុស្សធម៌ និងដោយថ្លៃថ្នូរ។[27] នៅពេលដែលសំណើសុំសិទ្ធិជ្រកកោនរបស់ពួកគេកំពុងដំណើរការ និងពួកគេមានវត្តមានស្របច្បាប់ អ្នកស្វែងរកសិទ្ធិជ្រកកោនទាំងនោះមានសិទ្ធិទទួលបានស្វ័យការងារ[28] និងមានសិទ្ធិជ្រើសរើសទីកន្លែងសម្រាប់រស់នៅ និងប្តូរទីតាំងដោយសេរីនៅក្នុងដែនដីរបស់រដ្ឋនោះ ដោយស្ថិតក្រោមបទដ្ឋាននានាដែលអនុវត្តលើជនបរទេសទូទៅដែរ។[29]

## គោលការណ៍នៃការមិនបញ្ជូនចេញដោយបង្ខំ

"**ការមិនបញ្ជូនចេញដោយបង្ខំ**" **ឬការហាមឃាត់ការបណ្តេញចេញ ឬការបញ្ជូនត្រឡប់វិញ** គឺជាគោលការណ៍មូលដ្ឋាននៃច្បាប់អន្តរជាតិស្តីពីជនភៀសខ្លួន។ គោលការណ៍ ដែលមានចែងក្នុងអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១ និងពិធីសារបន្ថែមឆ្នាំ១៩៦៧ នៃអនុសញ្ញានេះ ហាមឃាត់រដ្ឋពីការបញ្ជូនបុគ្គលទាំងឡាយត្រឡប់ទៅកាន់ប្រទេស ឬដែនដីទាំងឡាយណាដែលអាចគំរាមកំហែងដល់អាយុជីវិត ឬសេរីភាពរបស់អ្នកទាំងនោះ ទោះការបញ្ជូននោះធ្វើទៅក្នុងវិធីណាក៏ដោយ។[30] កាតព្វកិច្ចនេះនឹងអនុវត្តជានិច្ច ទោះបីបុគ្គលនោះទទួលបានឋានៈជាជនភៀសខ្លួន ឬមិនទាន់ទទួលបានក្តី។[31] ការវិវឌ្ឍនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិបានពង្រីកវិសាលភាពនៃកាតព្វកិច្ចនេះ ហើយបច្ចុប្បន្ននេះតម្រូវឱ្យរដ្ឋនានាត្រូវការពារបុគ្គលដែលមិនមែនជាពលរដ្ឋរបស់ខ្លួនពីការចាប់បញ្ជូនត្រឡប់ទៅកាន់ប្រទេស ដែលអាយុជីវិតរបស់បុគ្គលនោះអាចត្រូវរងការគំរាមកំហែង ឬទីកន្លែងដែលពួកគេប្រឈមនឹងអំពើទារុណកម្ម ឬអមនុស្សធម៌ និងការប្រព្រឹត្តមកលើខ្លួនដោយបន្ថោកបន្ទាប ដោយពុំគិតពីឋានៈជាជនអន្តោប្រវេសន៍របស់ពួកគេឡើយ។[32]

## ច្បាប់ជាតិ

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ")** ចែងថា ប្រទេសកម្ពុជា "*ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស [និង]*

---

[26] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន, "សេចក្តីណែនាំស្តីពីលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្ត និងបទដ្ឋានទាក់ទងទៅនឹងការឃុំខ្លួនលើអ្នកស្វែងរកសិទ្ធិជ្រកកោន និងជម្រើសផ្សេងក្រៅពីការឃុំខ្លួន", សេចក្តីណែនាំទី២ http://bit.ly/1lpfUQv

[27] ប្រភពខាងលើ សេចក្តីណែនាំទី៣, ទី៤ និងទី៦

[28] មាត្រា ១៨ នៃ អនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[29] មាត្រា ២៦ នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[30] មាត្រា ៣៣ (១) នៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ១៩៥១

[31] សូមមើលកំណត់ត្រារបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ស្តីពីការមិនបញ្ជូនចេញដោយបង្ខំ (ដែលបានដាក់ដោយឧត្តមស្នងការ) EC/SCP/2 ( ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧) កថាខ័ណ្ឌទី ៤ http://bit.ly/2qa0Sof

[32] អង្គការអន្តរជាតិដើម្បីជនភៀសខ្លួន, "កំណត់ត្រាព័ត៌មានអំពីគោលការណ៍នៃការមិនបញ្ជូនចេញដោយបង្ខំ" (ខែមេសា ឆ្នាំ២០១៤) http://bit.ly/2pbyrI7 សូមមើលឧទាហរណ៍ មាត្រា ៣ នៃអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម http://bit.ly/U5cWWq

*កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"* (មាត្រា៣១) ។ បន្ថែមលើនេះ បើតាមលទ្ធផលនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបានទទួលស្គាល់ថា សន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួចហើយអាចអនុវត្តដោយផ្ទាល់ក្នុងច្បាប់ជាតិ[33] ហេតុនេះកាតព្វកិច្ចរបស់កម្ពុជាក្រោមអនុសញ្ញាស្តីពីជនភៀសខ្លួន ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធច្បាប់ជាតិ។

ការបង្កើតនាយកដ្ឋានទទួលបន្ទុកជនភៀសខ្លួនក្នុងឆ្នាំ២០០៨ របស់កម្ពុជា គឺជាការវិវឌ្ឍជាវិជ្ជមានមួយ ដែលសង្ឃឹមថា នឹងធ្វើឱ្យកម្ពុជាក្លាយជាប្រទេសគំរូមួយក្នុងតំបន់។[34] ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលកម្ពុជា ដោយមានជំនួយពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានទទួលខុសត្រូវលើការទទួល និងការវិនិច្ឆ័យលើសំណើសុំសិទ្ធិជ្រកកោន។ ការវិវឌ្ឍជាវិជ្ជមានបន្ថែមទៀតនោះគឺការអនុម័ត "**អនុក្រឹត្យលេខ ២២៤ ឆ្នាំ២០០៩[35] ស្តីពីនីតិវិធីទទួលស្គាល់ឋានៈជាជនភៀសខ្លួន ឬ ការផ្តល់សិទ្ធិជ្រកកោនដល់ជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា**"("**អនុក្រឹត្យលេខ២២៤**") ដែល "ជាទូទៅស្របតាម"[36] និយមន័យនៃជនភៀសខ្លួនក្នុងអនុសញ្ញាឆ្នាំ១៩៥១ និងមានចែងបញ្ជាក់យ៉ាងច្បាស់ពីគោលការណ៍នៃការមិនបញ្ជូនចេញដោយបង្ខំ។[37] អនុក្រឹត្យនេះចែងថា ប្រសិនបើអ្នកស្នើសុំបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងអនុក្រឹត្យនេះ ពួកគេ"*នឹងទទួលបានឋានៈជាជនភៀសខ្លួន*"។ ដូច្នេះ អនុក្រឹត្យនេះផ្តល់នូវមូលដ្ឋានដែលប្រទេសកម្ពុជាអាចចាត់វិធានការវិជ្ជមានបន្ថែមទៀត ដើម្បីធានាឱ្យមានការគោរពយ៉ាងពេញលេញតាមកាតព្វកិច្ចរបស់ខ្លួន ដោយធានាពីដំណើរការកំណត់ឋានៈជាជនភៀសខ្លួនឱ្យមានតម្លាភាព និងត្រឹមត្រូវក្នុងការអនុវត្តជាក់ស្តែង។

---

33 ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

34 យិតជី ម៉ក្សយិនសី, "ប្រទេសកម្ពុជាកំពុងជិតក្លាយជាប្រទេសគំរូទទួលជនភៀសខ្លួនសម្រាប់តំបន់អាស៊ី", (ព័ត៌មានរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨) http://bit.ly/2ppn1AS

35 អនុក្រឹត្យលេខ ២២៤ http://bit.ly/2q5jrsL

36 ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន, "ឯកសារដាក់ស្នើដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន សម្រាប់ចងក្រងរបាយការណ៍របស់ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស - ការត្រួតពិនិត្យជាសាកលជាទៀងទាត់តាមពេលវេលាកំណត់" (ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/2pCKwYe ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ទទួលស្គាល់ការអនុម័តអនុក្រឹត្យលេខ ២២៤ ថាជា "ការវិវឌ្ឍដ៏សំខាន់មួយ និងគួរសរសើរប្រទេសកម្ពុជាដែលឈានមុខក្នុងការរៀបចំដំណើរការទាក់ទងនឹងការសុំសិទ្ធិជ្រកកោន" ខណៈដែលមានការគូសបញ្ជាក់ស្របពេលគ្នាអំពី "ការព្រួយបារម្ភមួយចំនួនទាក់ទងនឹងច្បាប់"។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិក៏យកចិត្តទុកដាក់លើបញ្ញត្តិមួយចំនួននៃអនុក្រឹត្យនេះដែរ៖ អង្គការឃ្លាំមើលសិទ្ធិមនុស្ស, "ការវិភាគជាបឋមអំពីអនុក្រឹត្យស្តីពីជនភៀសខ្លួន" (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០) http://bit.ly/2oItB6w

37 អនុក្រឹត្យលេខ ២២៤, មាត្រា ២៣

**ការវិភាគលើការប្រព្រឹត្តនាពេលថ្មីៗនៅលើម៉ុងតាញ៉ាដែលស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជា និងអនុសាសន៍**

ក្នុងខែធ្នូ ឆ្នាំ២០១៦ ម៉ុងតាញ៉ាចំនួន១៣នាក់ ត្រូវបានបញ្ជូន"ដោយស្ម័គ្រចិត្ត"ត្រឡប់ទៅប្រទេសវៀតណាមវិញ ក្រោយពីពាក្យស្នើសុំសិទ្ធិជ្រកកោនរបស់ពួកគេត្រូវបានច្រានចោល[38] បន្ទាប់មកមានម៉ុងតាញ៉ាមួយក្រុមទៀតមានគ្នា៦នាក់ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧។ មនុស្សចំនួន២៥នាក់ផ្សេងទៀតដែលបានភៀសខ្លួនមកកាន់ប្រទេសកម្ពុជាកាលពីពីរឆ្នាំមុន ក៏ត្រូវបានបញ្ជូនត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧។[39] រដ្ឋាភិបាលកម្ពុជា និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានថ្លែងថាក្រុមម៉ុងតាញ៉ាទាំងនោះយល់ព្រមត្រឡប់ទៅប្រទេសវៀតណាមវិញដោយស្ម័គ្រចិត្ត ប៉ុន្តែអ្នកវិលត្រឡប់មួយចំនួនបានឆ្លើយបដិសេធនឹងការលើកឡើងនេះ។[40] នៅដើមខែមេសា ឆ្នាំ២០១៧ ម៉ុងតាញ៉ាជិត ៥០ នាក់បានភៀសខ្លួនចេញពីកម្ពុជាទៅកាន់ប្រទេសថៃ បន្ទាប់ពីក្រសួងមហាផ្ទៃបានចាប់ផ្តើមច្រានចោលនូវសំណើសុំសិទ្ធិជ្រកកោនរបស់ពួកគេមួយចំនួន។ ជនភៀសខ្លួនទាំងនោះបានប្រាប់បណ្តាញសារព័ត៌មានថា ពួកគេបារម្ភថាពួកគេនឹងអាចប្រឈមនឹងការគាបសង្កត់ ការចាប់ខ្លួន ការធ្វើទារុណកម្ម ឬរហូតដល់អាចត្រូវគេសម្លាប់ ប្រសិនបើពួកគេត្រូវបានបញ្ជូនត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ។[41] នៅពេលនេះ អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាប្រមាណចំនួន ៧០ នាក់ កំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា។[42]

ដូចជាមានមន្ទិលថា តើអាជ្ញាធរកម្ពុជាកំពុងតែគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការបកស្រាយ និងអនុវត្តនិយមន័យនៃជនភៀសខ្លួនក្នុងអនុសញ្ញាឆ្នាំ១៩៥១ និងអនុក្រឹត្យលេខ២២៤ ដោយត្រឹមត្រូវ និងដោយស្មោះត្រង់ដែរឬយ៉ាងណា ដោយសារតែអ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាភាគតិចប៉ុណ្ណោះដែលសំណើរបស់ពួកគាត់ទទួលបានជោគជ័យក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ដោយសារមានការចងក្រងយ៉ាងជាក់ច្បាស់អំពីករណីនៃការធ្វើទុក្ខបុកម្នេញផ្នែកសាសនា និងនយោបាយដែលក្រុមម៉ុងតាញ៉ាទាំងនោះប្រឈមក្នុងប្រទេសវៀតណាម ទំនងជាការពិតដែលពួកគេហាក់ដូចជាបានបំពេញយ៉ាងពេញលេញតាមលក្ខខណ្ឌនៃ "ការភ័យ

---

38 វិទ្យុអាស៊ីសេរី, "កម្ពុជាបញ្ជូនម៉ុងតាញ៉ាមួយក្រុមត្រឡប់ទៅប្រទេសវៀតណាមវិញ" (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦) http://bit.ly/2pV5bTg

39 អូន ភាព និង ចច្ច រ៉ៃយ៍, "អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាចំនួន ៦នាក់ថែមទៀត ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ" ( ដឺ ខេមបូឌា ដេលី ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧) http://bit.ly/2m1izaS និង អ៊ើរីន ហែនលី និងឆាយ ចន្ទីដា, "អ្នកស្វែងរកសិទ្ធិជ្រកកោនត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ" (សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2oujjqc

40 ចច្ច រ៉ៃយ៍ និង អូន ភាព, "តិចម៉ុងតាញ៉ាដែលបានបញ្ជូនត្រឡប់ទៅវិញរិះគន់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាល", ដឺ ខេមបូឌា ដេលី ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2pjAlGU

41 ចច្ច រ៉ៃយ៍, "ជនភៀសខ្លួនម៉ុងតាញ៉ារៀបរាប់ពីការគេចខ្លួនទៅកាន់ប្រទេសថៃ", *ដឺ ខេមបូឌា ដេលី* (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2o6KJCw និង ហ្សេន ឆើតុន និង ផាក់ ស៊ាវលី, "ម៉ុងតាញ៉ាភៀសខ្លួនទៅកាន់ប្រទេសថៃ ដោយភ័យខ្លាចពីការធ្វើទុក្ខបុកម្នេញនៅប្រទេសវៀតណាម" (សារព័ត៌មានភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2pxLN2J

42 ចច្ច រ៉ៃយ៍ និង អូន ភាព, "តិចម៉ុងតាញ៉ាដែលបានបញ្ជូនត្រឡប់ទៅវិញរិះគន់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាល" ( *ដឺ ខេមបូឌា ដេលី* ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2pjAlGU

ខ្លាចមានមូលដ្ឋានច្បាស់លាស់" ចំពោះការធ្វើទុក្ខបុកម្នេញក្រោមអនុសញ្ញាស្តីពីជនភៀសខ្លួន និងមានសិទ្ធិទទួលបានការការពារក្នុងឋានៈជាជនភៀសខ្លួន។ ម្យ៉ាងទៀត អាជ្ញាធរកម្ពុជាបានផ្តល់ឋានៈជាជនភៀសខ្លួនឱ្យម៉ុងតាញ៉ាចំនួន១៣ នាក់ក្នុងឆ្នាំ២០១៥ តែចាប់ពីពេលនោះមកពុំទាន់មានភស្តុតាងបង្ហាញពីការប្រែប្រួលស្ថានភាពគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសវៀតណាម ដែលអាចផ្តល់ជាសម្អាងហេតុសមហេតុផលក្នុងការសន្និដ្ឋានថាហានិភ័យទាក់ទងនឹងការធ្វើទុក្ខបុកម្នេញនឹងលែងមានតទៅទៀតនោះទេ។[43] ក្នុងករណីណាក៏ដោយ ហើយថ្វីបើម៉ុងតាញ៉ាម្នាក់ៗត្រូវបានរកឃើញថាពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាជនភៀសខ្លួនយ៉ាងណាក្តី នោះច្បាស់ណាស់ថាកាតព្វកិច្ចនៃការមិនបញ្ជូនចេញដោយបង្ខំនឹងការពារអ្នកទាំងនោះពីការបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ខណៈការគំរាមកំហែងដល់អាយុជីវិត និងសេរីភាពអាចនឹងកើតឡើងចំពោះពួកគេ៖ ការបន្តបញ្ជូនក្រុមម៉ុងតាញ៉ាពីកម្ពុជាត្រឡប់ទៅវិញក្នុងកាលៈទេសៈទាំងនេះ គឺជាការរំលោភបំពានជាក់ស្តែងទៅលើគោលការណ៍ជាមូលដ្ឋាននៃច្បាប់ស្តីពីជនភៀសខ្លួន។[44]

ជាចុងក្រោយ ម៉ុងតាញ៉ាមួយចំនួនត្រូវបានរាយការណ៍ថាកំពុងស្ថិតក្នុងស្ថានភាពរស់នៅដ៏គួរឱ្យរឹតត្បិតនៅពេលស្ថិតនៅក្នុងប្រទេសកម្ពុជា រួមមានការតម្រូវឱ្យចុះបញ្ជីបីដងជារៀងរាល់ថ្ងៃជាមួយអាជ្ញាធរ និងការដាក់កំហិតទៅលើលទ្ធភាពរបស់ពួកគេក្នុងការចាកចេញពីកន្លែងស្នាក់នៅរបស់ខ្លួន។ [45] ការរឹតត្បិតហួសហេតុបែបនេះទៅលើសេរីភាពរបស់បុគ្គលដូចជាពុំបំពេញតាមលក្ខខណ្ឌនៃភាពចាំបាច់ ហើយមិនប្រាកដទេថាការឃ្លាំមើល ដែលមានលក្ខណៈជ្រៀតជ្រែកបែបនេះទៅលើការដើរហើររបស់អ្នកស្វែងរកសិទ្ធិជ្រកកោនអាចត្រូវបានផ្តល់សម្អាងហេតុត្រឹមត្រូវទៅបាន។ ជាពិសេស ការឃុំខ្លួនលើប្តីប្រពន្ធម៉ុងតាញ៉ាមួយគូអស់រយៈពេលប្រាំបីថ្ងៃក្នុងរាជធានីភ្នំពេញក្នុងស្ថានភាពមិនអំណោយផលដែលក្នុងនោះស្ត្រីជាប្រពន្ធមានផ្ទៃពោះបួនខែ [46] ទំនងជាបានរំលោភបំពានទៅលើលក្ខខណ្ឌដែលថាការឃុំខ្លួនណាមួយត្រូវធ្វើឡើងប្រកបដោយមនុស្សធម៌ និងថ្លៃថ្នូរ។[47]

---

[43] សូមមើល "របាយការណ៍សកលឆ្នាំ២០១៧" របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស នៅត្រង់ជំពូកស្តីពីប្រទេសវៀតណាម http://bit.ly/2oafjv6

[44] បន្ថែមលើការបញ្ជូនចេញដោយបង្ខំចំពោះអ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ា នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ កម្ពុជាបានបញ្ជូនអ្នកស្វែងរកសិទ្ធិជ្រកកោនអ៊ុយហ្គួរចំនួន២០នាក់ចេញដោយបង្ខំ ដែលអ្នកទាំងនេះត្រូវបានចាប់បញ្ជូនដោយបង្ខំទៅកាន់ប្រទេសចិនត្រឹមតែប៉ុន្មានថ្ងៃប៉ុណ្ណោះបន្ទាប់ពីកម្ពុជាបានអនុម័តអនុក្រឹត្យលេខ ២២៤។ សូមមើល "ឯកសារដាក់ស្នើដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន សម្រាប់ចងក្រងរបាយការណ៍របស់ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស - ការត្រួតពិនិត្យជាសាកលជាទៀងទាត់តាមពេលវេលាកំណត់" (ខែមិថុនា ឆ្នាំ២០១៣) http://bit.ly/2pCKwYe

[45] ចច្ច រ៉ែយ៍, "ជនភៀសខ្លួនម៉ុងតាញ៉ារៀបរាប់ពីការគេចខ្លួនទៅកាន់ប្រទេសថៃ" *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2o6KJCw

[46] ចច្ច រ៉ែយ៍ និង អូន ភាព, "ការឃុំខ្លួនប្តីប្រពន្ធម៉ុងតាញ៉ាមួយគូបង្កើតជាបញ្ហា" សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2opFFVQ និង អ៊េរីន ហែនលី និង ឆាយ ចន្ទីដា, "អ្នកស្វែងរកសិទ្ធិជ្រកកោនត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2oujjqc

[47] អ៊េរីន ហែនលី, "ផែនការនិរទេសខ្លួន "មិនត្រឹមត្រូវតាមច្បាប់"" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧) http://bit.ly/2pitFth

**អនុសាសន៍សម្រាប់រដ្ឋាភិបាលកម្ពុជា៖**

- **ធានាថាអ្នកស្វែងរកសិទ្ធិជ្រកកោនទាំងអស់នៅកម្ពុជាមានឱកាសដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោន និង ទទួលបានការសម្រេចប្រកបដោយយុត្តិធម៌ចំពោះសំណើសុំការការពាររបស់ពួកគេ** ដោយអនុលោមតាមច្បាប់អន្តរជាតិ និងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដៃគូអន្តរជាតិដទៃទៀត ព្រមទាំងសង្គមស៊ីវិលដើម្បីសម្រេចកិច្ចការនេះ។
- គោរពតាមកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួនក្នុងឋានៈជារដ្ឋភាគីនៃអនុសញ្ញាស្តីពីជនភៀសខ្លួន និងក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេស **គោរពឱ្យបានពេញលេញតាមគោលការណ៍ជាមូលដ្ឋាននៃការមិនបញ្ជូនចេញដោយបង្ខំ និងដាក់ចេញបទបញ្ជាភ្លាមៗដើម្បីផ្អាកជាបណ្តោះអាសន្នចំពោះការធ្វើមាតុភូមិនិវត្តន៍អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ា និងជនភៀសខ្លួនផ្សេងៗ** (បើទោះដោយ "ស្ម័គ្រចិត្ត" ក៏ដោយ) រហូតទាល់តែអ្នកសង្កេតការណ៍អន្តរជាតិអាចធ្វើការឃ្លាំមើលប្រកបដោយប្រសិទ្ធភាពជាបន្តបន្ទាប់ទៅលើស្ថានភាពរបស់ក្រុមម៉ុងតាញ៉ាដែលបានបញ្ជូនត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ ដើម្បីធានាថាជីវិត ឬសេរីភាពរបស់ពួកគេនឹងមិនត្រូវបានគំរាមកំហែង។
- **ធានាថាការប្រព្រឹត្តទៅលើអ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួនទាំងឡាយនៅកម្ពុជាអនុលោមតាមបទដ្ឋានអន្តរជាតិ** ជាពិសេស ធានាថា ការរឹតត្បិតណាមួយទៅលើការដើរហើររបស់អ្នកស្វែងរកសិទ្ធិជ្រកកោនបំពេញតាមលក្ខខណ្ឌនៃភាពចាំបាច់ក្រោមអនុសញ្ញាស្តីពីជនភៀសខ្លួន និងថាការឃុំខ្លួននោះត្រូវធ្វើឡើងជាជម្រើសចុងក្រោយប៉ុណ្ណោះ ដោយជនជាប់ឃុំត្រូវស្ថិតក្នុងលក្ខខណ្ឌមនុស្សធម៌ និងថ្លៃថ្នូរ។

**អនុសាសន៍សម្រាប់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន៖**

- **អំពាវនាវដល់រដ្ឋាភិបាលវៀតណាមអនុញ្ញាតឱ្យបានពេញលេញ និងមិនមានការរឹតត្បិតចំពោះអ្នកសង្កេតការណ៍អន្តរជាតិ**ដើម្បីចូលទៅកាន់តំបន់ដែលជនភៀសខ្លួនម៉ុងតាញ៉ាធ្លាប់បានរស់នៅពីមុន ឬកន្លែងដែលពួកគេត្រូវគេបញ្ជូនត្រឡប់ទៅវិញ។
- **បញ្ឈប់ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍អ្នកស្វែងរកសិទ្ធិជ្រកកោនម៉ុងតាញ៉ាពីប្រទេសកម្ពុជា** (ទោះបីជាដោយ "ស្ម័គ្រចិត្ត" ឬមិនក្តី) រហូតទាល់តែអ្នកឃ្លាំមើលអន្តរជាតិអាចធ្វើការឃ្លាំមើលប្រកបដោយប្រសិទ្ធភាពជាបន្តបន្ទាប់ទៅលើស្ថានភាពរបស់ក្រុមម៉ុងតាញ៉ាដែលត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ដើម្បីធានាថាជីវិត ឬសេរីភាពរបស់ពួកគេនឹងមិនត្រូវរងការគំរាមកំហែង។
- **អំពាវនាវដល់អាជ្ញាធរកម្ពុជាឱ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិស្តីពីជនភៀសខ្លួន និងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា** ព្រមទាំងលើកឡើងអំពីការរំលោភបំពានណាមួយដែលកើតឡើងពាក់ព័ន្ធនឹងបញ្ហាជនភៀសខ្លួននេះ ជាពិសេស ធានាថាមានការកំណត់ឋានៈជាជនភៀសខ្លួនត្រូវបាន

ធ្វើឡើងយ៉ាងត្រឹមត្រូវ និងអនុលោមតាមច្បាប់ និងថាការប្រព្រឹត្តទៅលើអ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួននៅកម្ពុជាស្របតាមបទដ្ឋានអន្តរជាតិ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ឌុច ពិសិដ្ឋ នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ +៨៥៥(០) ១២ ៧១ ២៣ ៧១ ឬ អ៊ីម៉ែល ៖ duchpiseth@cchrcambodia.org៕**

CC BY NC SA